01300191

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 28 / 06 / 2016
ម៉ោង (Time/Heure) : 10:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Sann Rada

E421

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦

**ជូនចំពោះ៖** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** ដំណាក់កាលចុងក្រោយនៃសំណុំរឿង ០០២/០២ - ការជូនដំណឹងអំពីកាលបរិច្ឆេទផ្សេងៗ

១. អង្គជំនុំជម្រះសាលាដំបូងសូមជូនដំណឹងដល់ភាគីនានាថា អង្គជំនុំជម្រះគ្រោងនឹងបញ្ចប់សវនាការដេញដោលលើភស្តុតាងនៅក្នុងសំណុំរឿង ០០២/០២ នៅត្រឹមខែ ធ្នូ ឆ្នាំ ២០១៦។ ផ្អែកតាមកាលបរិច្ឆេទនេះ អង្គជំនុំជម្រះសូមផ្តល់ការណែនាំអំពីដំណាក់កាលចុងក្រោយនៃសំណុំរឿងនេះ ដូចតទៅ ៖

២. **<u>សវនាការអំពីផលប៉ះពាល់ និង ស្ថានភាពព្យសនកម្មទៅលើដើមបណ្តឹងរដ្ឋប្បវេណី</u>៖** អង្គជំនុំជម្រះសូមរម្លឹកថា អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីអំពីបញ្ជីឈ្មោះបុគ្គលដែលត្រូវបានជ្រើសរើសឱ្យមកផ្តល់សក្ខីកម្មលើប្រធានបទនៃការចេញបទបញ្ជារៀបអាពាហ៍ពិពាហ៍ រួមមាន ដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រាំបីនាក់ សាក្សីចំនួនពីរនាក់ និង អ្នកជំនាញចំនួនពីរនាក់។

ដោយពិចារណាទៅលើចំនួនដ៏ច្រើននៃដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានជ្រើសរើស និង ឱកាសដើម្បីបង្ហាញពីស្ថានភាពទុក្ខសោកវេទនារបស់ពួកគាត់នោះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនឹងទទួលបានរយៈពេលមួយថ្ងៃ (ជំនួសឱ្យរយៈពេលពីរថ្ងៃ) សម្រាប់សវនាការអំពីផលប៉ះពាល់ និង ស្ថានភាពព្យសនកម្មលើដើមបណ្តឹងរដ្ឋប្បវេណីក្នុងប្រធានបទនេះ។ មានតែប្រធានបទពីរផ្សេងទៀតប៉ុណ្ណោះ គឺលក្ខណៈនៃជម្លោះប្រដាប់អាវុធ និង តួនាទីរបស់ជនជាប់ចោទ ដែលស្ថិតនៅក្រោមការពិចារណានៅក្នុងសំណុំរឿង ០០២/០២ (ឯកសារ E315)។ អង្គជំនុំជម្រះយល់ឃើញថា ប្រធានបទចុងក្រោយទាំងពីរនេះ មិនតម្រូវឱ្យមានសវនាការស្តីអំពីផលប៉ះពាល់ និង ស្ថានភាពព្យសនកម្មទៅលើដើមបណ្តឹងរដ្ឋប្បវេណីឡើយ។ ហេតុនេះ សវនាការអំពីផលប៉ះពាល់ និង ស្ថានភាពព្យសនកម្មទៅលើដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងការចេញបទបញ្ជារៀបអាពាហ៍ពិពាហ៍ គឺជាសវនាការចុងក្រោយនៅក្នុងសំណុំរឿង ០០២/០២ (ឯកសារ E315/1 កថាខណ្ឌ ៧)។

៣. <u>**ពេលវេលាកំណត់ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង**</u>៖ អង្គជំនុំជម្រះកត់សម្គាល់ថា ភាគីបានដាក់សំណើអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធទៅនឹងសាក្សី និង ឯកសារថ្មីៗតាមដំណាក់កាលនៃសំណុំរឿង ០០២/០២។ ការដាក់សំណើទាំងនេះឱ្យទាន់ពេលវេលា និង ការយកចិត្តទុកដាក់ដ៏ត្រឹមត្រូវរបស់ភាគីដែលស្នើសុំឱ្យទទួលយកភស្តុតាងថ្មី គឺជាការពិចារណាដ៏សំខាន់នៅក្នុងការសម្រេចថាតើភស្តុតាងដែលស្នើសុំនោះគួរត្រូវបានទទួលយក ឬ យ៉ាងណា។ ដោយសារតែអង្គជំនុំជម្រះជិតបញ្ចប់សវនាការដេញដោលលើភស្តុតាងនៅក្នុងសំណុំរឿង ០០២/០២ ហើយនោះ ការពិចារណាទាំងនេះកាន់តែមានសារៈសំខាន់ឡើង ពីព្រោះភាគីត្រូវទទួលបានការជូនដំណឹងគ្រប់គ្រាន់អំពីភស្តុតាងណាដែលអាចមានសារៈសំខាន់ដល់រឿងក្តីរបស់ខ្លួន និង ពេលវេលាគ្រប់គ្រាន់ក្នុងការឆ្លើយតបទៅនឹងភស្តុតាងនោះនៅមុនពេលបិទបញ្ចប់សវនាការដេញដោលលើភស្តុតាង។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះយល់ឃើញថា ត្រូវតែកំណត់ពេលវេលាសម្រាប់ការស្នើសុំឱ្យទទួលយកភស្តុតាងថ្មីនៅក្នុងសំណុំរឿង ០០២/០២ និង ជូនដំណឹងដល់ភាគីថា រាល់សំណើសុំ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងនៅក្នុងរឿងក្តីនេះត្រូវតែដាក់យ៉ាងយូរបំផុតត្រឹម<u>**ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៦**</u>។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះនឹងពិចារណាលើសំណើសុំឱ្យទទួលយកភស្តុតាងថ្មី

ដែលបានរកឃើញក្រោយពេលបានកំណត់នេះ ឬ សំណើសុំឱ្យទទួលយកភស្តុតាងដែលជាភស្តុតាងដោះបន្ទុក (ឯកសារ E363/3 កថាខណ្ឌ ២៣-២៤)។

៤. **ភស្តុតាងអំពីអត្តចរិត៖** សាក្សីដែលត្រូវផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០២ ពាក់ព័ន្ធនឹងអត្តចរិតជនជាប់ចោទនឹងត្រូវកំណត់កាលបរិច្ឆេទ បន្ទាប់ពីប្រធានបទសវនាការចុងក្រោយនៅក្នុងរឿងក្តីនេះ (ដែលជាប្រធានបទស្តីពីតួនាទីរបស់ជនជាប់ចោទ)។ អង្គជំនុំជម្រះរម្លឹកថា មេធាវីការពារក្តី ខៀវ សំផន មិនបានស្នើសុំឱ្យកោះហៅសាក្សីអត្តចរិតណាម្នាក់នៅក្នុងសំណុំរឿង ០០២/០២ ឡើយ (ឯកសារ E305/5 *និង ឯកសារផ្សេងៗទៀត*)។ មេធាវីការពារក្តី នួន ជា បានស្នើសុំឱ្យកោះហៅសាក្សីអត្តចរិតចំនួនបីនាក់ (2-TCW-831, 2-TCW-877, 2-TCW-962) ទោះបីជាសាក្សីទាំងនេះត្រូវបានស្នើសុំឱ្យកោះហៅមកផ្តល់សក្ខីកម្មលើប្រធានបទផ្សេងទៀតក៏ដោយ (ឯកសារ E305/4 *និង ឯកសារផ្សេងៗទៀត*)។ សេចក្តីសម្រេចលើសំណើសុំទាំងនេះនឹងត្រូវចេញនៅក្នុងពេលសមស្របខាងមុខ។

៥. **សារណា និង សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល៖** ជាបឋម អង្គជំនុំជម្រះជូនដំណឹងដល់ភាគីថា អង្គជំនុំជម្រះនឹងស្នើសុំឱ្យដាក់សារណាជាមុនដែលលើកឡើងអំពីច្បាប់ជាធរមានក្នុងគោលបំណងមួយចំនួន រួមទាំង (១) ដើម្បីបន្ថែមទៅលើសេចក្តីសន្និដ្ឋានពីមុនៗ ផ្នែកលើការវិវត្តថ្មីៗផ្នែកច្បាប់ និង (២) ដើម្បីធ្វើសេចក្តីសន្និដ្ឋានអំពីឧក្រិដ្ឋកម្ម និង ទម្រង់នៃការទទួលខុសត្រូវដែលមិនមែនជាផ្នែកនៃសំណុំរឿង ០០២/០១។ ការដាក់សារណានឹងត្រូវកំណត់កាលបរិច្ឆេទបន្ទាប់ពីមានការចេញសាលដីកាលើសំណុំរឿង ០០២/០១។ បន្ទាប់មក សារណាបញ្ចប់ការពិភាក្សាដេញដោលនឹងមានរយៈពេលកំណត់ពីរខែ បន្ទាប់ពីការបិទបញ្ចប់សវនាការដេញដោលលើភស្តុតាង។ សេចក្តីសន្និដ្ឋានផ្ទាល់មាត់បញ្ចប់ការពិភាក្សាដេញដោលនឹងត្រូវធ្វើឡើងក្នុងរយៈពេលមួយខែ ក្រោយពេលដែលភាគីដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ។ អង្គជំនុំជម្រះនឹងមិនទទួលចម្លើយតបជាលាយលក្ខណ៍អក្សរឡើយ។ ដូចនៅក្នុងសំណុំរឿង ០០២/០១ ដែរ សារណាបញ្ចប់ការពិភាក្សាដេញដោលនឹងត្រូវដាក់តែមួយភាសា។ ភាគីនានាត្រូវពឹងផ្អែកទៅលើសមត្ថភាពបុគ្គលិកផ្ទៃក្នុងរបស់ខ្លួនដែលចេះច្រើនភាសា (ឯកសារ E295/7/2 កថាខណ្ឌ ៤)។ ទោះបីជាយ៉ាងណាក៏ដោយ ភាគីនឹងទទួលបានជំនួយផ្នែកបកប្រែភាសា

ពីអង្គភាពបកប្រែភាសា នៅចន្លោះពេលដាក់សារណា និង ការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល (ឯកសារ E295/4 កថាខណ្ឌ ៥)។ អង្គជំនុំជម្រះនឹងមិនរង់ចាំការបញ្ចប់ការបកប្រែសារណាទាំងនោះ មុនពេលស្តាប់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សារដេញដោលនោះឡើយ ពីព្រោះថា ការធ្វើបែបនេះអាចបណ្តាលឲ្យមានការពន្យារពេលមិនសមស្រប (ឯកសារ (E295/7/2)។ ដើម្បីងាយស្រួលក្នុងការយោង ភាគីត្រូវប្រើជើងទំព័រ (មិនមែនចុងទំព័រទេ)។ ព័ត៌មានបន្ថែមស្តីអំពីសារណាបញ្ចប់ការពិភាក្សាដេញដោល រួមទាំងការកំណត់ចំនួនទំព័រ និងសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល នឹងត្រូវផ្តល់ជូននៅក្នុងពេលសមស្របខាងមុខ។